ក្បួនខ្នាត

ខ្លះនៃ

# សំណង់ក្នុងបរិវេណវត្តអារាម

គួ សុជា

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

ព.ស. ២៥៤៥ គ.ស. ២០០១

២១៤.
៦៧

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh      www.elibraryofcambodia.org

២១៤.៦៧

ក្បួនខ្នាត

ខ្លះនៃ

# សំណង់ក្នុងបរិវេណវត្តអារាម

ភូ សុផា

INSTITUT BOUDDHIQUE
បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
៥៧០៤/០១

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស.២៥៤៥ គ.ស.២០០១

www.budinst.gov.kh www.elibraryofcambodia.org

## សេចក្ដីបញ្ជាក់
## ចំពោះការបោះពុម្ព

សៀវភៅ " ក្បូនខ្នាតខ្លះនៃសំណង់ ក្នុងបរិវេណវត្តអារាម " នេះត្រូវបានបោះពុម្ពដោយបាន ទទួលការឧបត្ថម្ភពីអង្គការ សេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់ DED ។

គោលបំណងនៃការបោះពុម្ពសៀវភៅនេះ គឺ :

- ដើម្បីជាប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវ និងការយល់ដឹងអំពីទម្រង់, ខ្នាត ចំពោះសំណង់នៅក្នុងវត្ត ។

- ដើម្បីជំរុញបញ្ញាវន្តជំនាន់ក្រោយ ឱ្យមានសេចក្ដីក្លាហានក្នុងការបញ្ចេញស្នាដៃរបស់ខ្លួន និងតម្កើងសម្បត្តិវប្បធម៌ អក្សរសាស្ត្រ បន្តគង់វង្ស ។

ការបោះពុម្ពនេះ ធ្វើឡើងដោយផ្អែកលើឯកសារច្បាប់ដើម ដែលជានិក្ខេបបទ របស់លោក ភូ សុជា ទាំងស្រុង ។ ហេតុនេះ ប្រសិនបើមានកំហុសក្នុងការរៀបរៀងឃ្លាក្ដី កំហុសបច្ចេកទេសក្ដី នោះគឺជាលក្ខណៈដែលមាននៅក្នុងនិក្ខេបបទ ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសទុកជាមុន ចំពោះកង្វះខាតផ្សេងៗ ដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពនេះ ។

ភ្នំពេញ, ខែ កក្កដា ឆ្នាំ ២០០១

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

www.budinst.gov.kh www.elibraryofcambodia.org

# មាតិកា


| | ទំព័រ |
|---|---|
| ១. កថាមុខ | ១ |
| ២. សេចក្ដីផ្ដើម | ៣ |
| ៣. ប្រវត្តិវត្តអារាម | ៥ |
| ៤. ការពន្យល់ពាក្យខ្លះៗ | ៧ |
| ៥. ទំនៀមទំលាប់ និងក្បូនខ្នាតខ្លះៗ | ១០ |
| ៥.១ ការតាំងទីថ្មី | ១០ |
| ៥.២ ការរៀបចំសំណង់ក្នុងទីវត្ត | ១០ |
| ៥.៣ ការប្រើប្រាស់ពណ៌ | ១១ |
| ៥.៤ ព្រះវិហារ | ១៣ |
| ៥.៤.១ ការបែរទិស | ១៣ |
| ៥.៤.២ ជើង (ទី១-២-៣) | ១៤ |
| ៥.៤.៣ សសរ | ១៧ |
| ៥.៤.៤ ផែរ៉ា | ១៨ |
| ៥.៤.៥ រនស្សូរ | ២៤ |
| ៥.៤.៦ ក្បឿង | ២៦ |
| ៥.៤.៧ ខាត-ជហ្វា | ២៧ |
| ៥.៤.៨ ហោជាង | ៣០ |
| ៥.៥ ហោត្រៃ ឬហោព្រៃ | ៥៧ |
| ៥.៦ សាលាឆាន់ | ៧៥ |
| ៥-៧ ទំរង់ក្បាច់ខ្លះ | ៩៣ |
| ៥-៨ ខ្នាតព្រះពុទ្ធរូប | ១១៣ |


www.budinst.gov.kh www.elibraryofcambodia.org

## ១. កថាមុខ

សៀវភៅឈ្មោះ "ក្បួនខ្នាតខ្លះនៃសំណង់ក្នុងបរិវេណវត្តអារាម" នេះបានប្រសូត្រឡើងមិនសំរាប់តែជាជំនួយដល់អ្នកសិក្សាប៉ុណ្ណោះ ជាពិសេសការកសាងសង់សំណង់បំរើសាសនាឱ្យគោរពតាមក្បួនខ្នាតបានត្រឹមត្រូវ ចៀសវាងការស្អាបអាឡើងតាមអំពើចិត្តនឹកឃើញ ដោយពុំមានមូលដ្ឋានគ្រឹះសោះនោះ ជាហេតុនាំឱ្យកើតមានភាពអាណាធិបតេយ្យគ្មានសណ្តាប់ធ្នាប់ គ្មានរបៀបរៀបរយអាគារតាមមុខងារបំរើបំរះនិមួយៗរបស់វាឡើយ ។

សំណង់វត្តអារាម នៅស្រុកយើងសព្វថ្ងៃនេះបាននិងកំពុងរីកដុះដាលច្រើនស្ទេកណ្តះ សមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលកាន់ និងគោរពសាសនាព្រះពុទ្ធជា សាសនារបស់រដ្ឋ ។ ប៉ុន្តែប្រសិនបើក្រឡេកមើលសំណង់ទាំងអស់សង់ឡើងនៅក្នុងបរិវេណវត្ត ភាគច្រើនជាសំណង់ក្លាយ មិនត្រឹមត្រូវតាមក្បួនខ្នាតទេ លើសពីនេះទៅទៀតគឺការប្រើប្រាស់សំភារៈសំណង់ខុសដូចជា: អិដ្ឋការ៉ូហ្វាយ៉ង់ដែលគេសំរាប់សំអាតលំនៅឋាន ក្នុងបន្ទប់ទឹក ។ល។ ត្រលប់យកទៅបិទលើដំបូលព្រះវិហារជំនួសក្បឿងស្រកានាគឥដ្ឋប្រណិតទៅវិញ ។ ទាំងនេះជាកំហុសមួយ យ៉ាងធំដែលតំរូវតាមចិត្តចង់របស់បុគ្គល ដោយពុំបានយកមកគិតពិចារណាថា តើកសាងឡើងសំរាប់ធ្វើអ្វី ?

យើងទាំងអស់គ្នាមានកំណើតកើត និងបានរស់នៅលើដែនដី ពោរពេញទៅដោយកេរ្តិ៍មរតកពីដូនតាបន្សល់ទុកឱ្យយើងនេះ ជាប្រយោជន៍ដ៏សំខាន់សំរាប់ជនជាតិខ្មែរគ្រប់រូបដែលមានភក្តីភាពសាសនា និងទទួលយកសមិទ្ធិផលទាំងអស់នេះ ។ ហេតុដូច្នេះខ្មែរត្រូវតែបន្តទំនៀមទំលាប់ផងទាំងពួងដែលពួកយើងមាន កុំឱ្យសាបសូន្យអស់ពីទឹកដីភូមិចាស់របស់យើង ព្រោះថាដូនតាលោកធ្វើ ឬ សាងសំណង់ឡើងគឺមានក្បួនខ្នាតត្រឹមត្រូវ គឺសំណង់សំរាប់បំរើបំរះការរស់នៅរបស់មនុស្ស និងសំណង់សំរាប់គោរពបូជាដល់សាសនា ។ សំណង់ទាំងពីរប្រភេទនេះមានលក្ខណៈខុសពីគ្នាដាច់ស្រឡះ ។

សរុបសេចក្តីមកសៀវភៅនេះ គ្រាន់តែជាមាតិកាចាស់ដែលបានពីការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សារបស់ខ្ញុំ សុំឱ្យបន្តតាមក្បួនខ្នាតដែលមានស្រាប់កុំបំភ្លេចវាចោល ។ ម្យ៉ាងទៀតក៏ជាជំនួយដល់អ្នកសិក្សាជំនាន់ក្រោយសំរាប់ស្រាវជ្រាវបន្ថែមនូវអ្វីដែលខ្វះចន្លោះ ។



www.budinst.gov.kh www.elibraryofcambodia.org

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងឱ្យស្រុក និងអ្នកស្រុកខ្មែរទាំងមូលបានស្ងប់ស្ងៀមគង់វង្ស និងប្រកប ដោយសេចក្ដីសុខចំរើនគ្រប់ប្រការ ! ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះ :

-សាស្ត្រាចារ្យ **ទៅ សាវឿន**

ដែលបានជួយកែពាក្យ និងជួយរៀបរៀងអត្ថបទ ។

-សាស្ត្រាចារ្យក្នុងសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលបានចំណាយពេល វេលាមានតំលៃក្នុងពេលការពារគំរោងបញ្ចប់ឆ្នាំសិក្សា ។

-លោកគ្រូ **ឃុ សិរីមេឍ**

ដែលបានជួយមើលកែប្លង់ និងផ្ដល់រូបថតមួយចំនួន ។

-លោកតាអាចារ្យ និងឧបាសក ឧបាសិកាក្នុងវត្តស្វាយ វត្តដំណាក់ វត្តឥន្ទកោសិ ឥន្ទកោសា ដែលបានជួយស្រាវជ្រាវផ្ដល់ព័ត៌មាន ។

-វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលបានទទួលរ៉ាប់រងក្នុងការបោះពុម្ពផ្សាយ ។

-អង្គការ អាល្លឺម៉ង់ដែលផ្ដល់ថវិការ សំរាប់បោះពុម្ព

-លោក ចាប ចំរើន ដែលបានផ្ដល់រូបមួយចំនួន

សៀមរាប, ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០០

ភ្ញ សុផា



www.budinst.gov.kh www.elibraryofcambodia.org

## ២.សេចក្តីផ្តើម

ពិភពលោកនេះមានវិសាលភាពធំទូលាយណាស់ បានផ្តល់ទានដល់សត្វលោកទាំងឡាយឱ្យរស់រានមានជីវិតបាន ជាពិសេសគឺសត្វមនុស្សដែលជាសមិទ្ធិផលដ៏ប្រសើរបំផុតរបស់ធម្មជាតិ ។ ម្យ៉ាងទៀតមនុស្សជាសត្វលោកមានប្រាជ្ញា វិចារណញ្ញាណលើសសត្វនានា ដោយចេះកែច្នៃធម្មជាតិតាមរយៈប្រើប្រាស់បញ្ញាណលក្ខនិងហត្ថកម្មដើម្បីរស់នៅឱ្យសមស្របទៅនឹងបរិស្ថានធម្មជាតិ ។

កាលពីសម័យបុរាណ មនុស្សពុំទាន់ចេះសាងសង់លំនៅឋានទេ ដោយសារមានវេទនារម្មណ៍ពីធម្មជាតិមិនអាចទ្រាំរស់នៅកណ្តាលវាលបានដូចជា បញ្ហាអាកាសធាតុនិងសត្វសាហាវជាច្រើនផងនោះ មនុស្សក៏នាំគ្នាទៅរស់នៅក្នុងល្អាងភ្នំជាជំរករបស់ខ្លួន ។

ក្រោយមកដោយមានការវិវត្តន៍ផ្នែកហត្ថពលកម្ម និងប្រាជ្ញាញាណមនុស្សក៏ចេះសង់ផ្ទះសំបែង ជំរក បង្កើតជាសង្គម មានរដ្ឋ មានទីក្រុង មានប្រាសាទ និងវត្តអារាម ។ល។ លទ្ធផលនៃសេចក្តីព្យាយាមយកចិត្តទុកដាក់របស់មនុស្ស បានបង្កើតឱ្យមានគំនិតច្នៃប្រឌិតដែលមានលក្ខណៈជាសិល្បៈសាច់ឈាម និងគំនិត ហើយបង្កប់នូវមនោគមវិជ្ជា ជំនឿសាសនា ច្បាប់ទំលាប់ប្រពៃណីជាដើម ។

វិស័យស្ថាបត្យកម្មមុនសម័យអង្គរ គឺពីសម័យភ្នំដា រហូតដល់សម័យកុលេន ស្ថាបនិកបានប្រើប្រាស់ឥដ្ឋ និងថ្មបាយក្រៀមសំរាប់ធ្វើប្រាសាទ លើកលែងតែគ្រឿងលំអស្ថាបត្យកម្ម មានក្បាច់រូបចំលាក់ផ្តែរ សសរពេជ្រ .... ដែលយកថ្មភក់មកប្រើប្រាស់ ។ នៅសតវត្សទី៩ រជ្ជកាលរស់ឡើងវិញ នៃអតីតមហាណាចក្រចេនឡាជាប្រភពកើតឡើងនូវអរិយធម៌ខ្មែរអង្គរ ។ ព្រះបាទជ័យវរ្ម័នទី ២ បានប្រមូលសិល្បករល្បីៗ ទាំងអស់ដើម្បីបង្កើតស្នាដៃមួយថ្មីស្រឡាង ។

នេះជាចំនុចចាប់ផ្តើមមួយ ដែលធ្វើឱ្យមនុស្សខ្មែរ សិល្បករខ្មែរបានប្រមូលផ្តុំគ្នាដកស្រង់បទពិសោធន៍ពីគ្នាទៅវិញទៅមក ហើយកែច្នៃសិល្បៈខ្លួនឯងឱ្យមានសុក្រិតភាព និងមានលក្ខណៈជាតិខ្មែរពិតៗ ។ រហូតដល់សម័យអង្គរ វិស័យស្ថាបត្យកម្មខ្មែរឈានដល់កំរិតកំពូល ដែលមានប្រាសាទអង្គរវត្ត និងប្រាសាទបាយ័ន ជាភស្តុតាងដ៏ល្បីល្បាញ នៅក្នុងលោកយើងនេះ ។

ប្រាសាទត្រូវបានកសាងឡើងដោយមានទំហំធំ ហើយខ្ពស់មានថែវព័ទ្ធជុំវិញ និងមានគូរទឹកព័ទ្ធពីក្រៅ ដែលមានរចនាលំអរតាំងពីថ្នល់រហូតដល់កំពូលប្រាសាទ ។ ក្នុងរាជស្តេចជ័យវរ្ម័ន ៧



www.budinst.gov.kh www.elibraryofcambodia.org

ជាសម័យកាលផ្លាស់ប្តូរពីព្រហ្មញ្ញសាសនា មកព្រះពុទ្ធសាសនា ពុទ្ធប្រាសាទទាំងឡាយ សាងសង់ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធសាសនា ។

ចាប់តាំងពីសម័យបាយ័នទៅ វិស័យស្ថាបត្យកម្មបានផ្លាស់ប្តូរទាំងស្រុង ប្រជាជនខ្មែរយើងបាន ទទួលយកនូវលទ្ធិព្រះពុទ្ធសាសនាថេរវាទជាផ្លូវការ ហេតុនេះស្ថាបត្យកម្មខ្មែរបានផ្លាស់ប្តូរពីសំណង់សង់អំពីឥដ្ឋ ថ្មបាយក្រៀម ថ្មភក់ មកសង់អំពីឈើវិញ។ សិល្បករ ស្ថបត្យករ បាននាំគ្នាសាងសង់វត្តអារាម ជំនួសប្រាសាទវិញ ដោយកំនត់ទីកន្លែងធំៗ សំរាប់ទទួលយកឧបាសក ឧបាសិកា ក្នុងការគោរពបូជាព្រះពុទ្ធសាសនា ។ កាលពីសម័យសៀមកាន់កាប់ក្រុងអង្គរជាបណ្តោះអាសន្ន ក្នុងឆ្នាំ ១៤៣១ ប្រជាជនបានចាកចេញពីក្រុងអង្គរ ដោយនាំបន្តស្នាដៃសិល្បៈជាប្រពៃណីរបស់ខ្លួនទៅស្រីសន្ធរ ។ ចំណែកឯជំនឿព្រះពុទ្ធសាសនានេះត្រូវបានអ្នកស្រុកយើងគោរពជាប្រចាំរហូតមកទល់សព្វថ្ងៃនេះ ។

សំណង់សាសនាជាគ្រឹះនៃវប្បធម៌ ជាប្រពៃណី និងជាព្រលឹងជាតិខ្មែរ ក៏ប៉ុន្តែគួរឱ្យសោកស្តាយជាទីបំផុត ដោយសារប្រទេសជាតិយើងបានជួបប្រទះនូវសង្គ្រាមជាញឹកញាប់នាំឱ្យស្នាដៃសិល្បៈ វប្បធម៌ខ្មែរត្រូវចុះខ្សោយអស់ជាពិសេសគឺសំណង់វត្តអារាមដ៏ចំណាស់ៗ ជាច្រើនដែលសាងសង់អំពីឈើ ត្រូវបាក់បែកពុកផុយស្ទើរគ្មានសល់ ។

អាស្រ័យលើការទ្រុឌទ្រោមដូចបានអធិប្បាយខាងលើ ហើយស្របតាមគោលនយោបាយ របស់រដ្ឋាភិបាល និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលកំពុងខិតខំស្តារ និងការពារវប្បធម៌ខ្មែរដែលត្រូវបានលិចលង់អស់ជាច្រើនទសវត្សកន្លងមកនេះ ។ ក្នុងខណៈបញ្ចប់ការសិក្សាផ្នែក ស្ថាបត្យកម្ម នៃមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយវិទ្យា ឆ្នាំ១៩៩០-១៩៩៧ ខ្ញុំបានជ្រើសរើសយកប្រធានបទស្តីអំពីសំណង់សាសនា គឺសិក្សាពីរចនាសម្ព័ន្ធរបស់សំណង់នៅក្នុង បរិវេណវត្តអារាម មានគោលបំណងចូលរួមចំណែកក្នុងការស្តារ និងការពារវប្បធម៌ខ្មែរដែល ធ្លាប់តែមានកិត្តិស័ព្ទល្បីល្បាញ តាំងពីយូរលង់ណាស់មកហើយ ។ ម្យ៉ាងទៀតដើម្បីស្វែងយល់ផង បង្កើតឯកសារសំរាប់ចំណេះដឹងផ្ទាល់ខ្លួនផង និងជាជំនួយខ្លះៗ សំរាប់អ្នកសិក្សាជំនាន់ក្រោយៗផង ហើយខ្ញុំសង្ឃឹមថាទុកគ្រាន់ជាគំរូសំរាប់ការសាងសង់ផងដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

## ៣. ប្រវត្តិវត្តអារាម

(ស្រាវជ្រាវតាមសិលាចារឹក)

កាលសម័យដើម តាមការសិក្សាស្រាវជ្រាវបានដឹងថា ៖ ឯកសារទាំងឡាយដែលបុព្វបុរសយើងបានរក្សាទុកឱ្យគឺមានតែអក្សរចំណារលើសិលាចារឹកជាភាសាសំស្ក្រឹត និងខ្មែរបុរាណទុកតរៀងមកដែលជាភស្តុតាងរបស់ប្រវត្តិសាស្ត្រផង និងជាប្រភពអក្សរសាស្ត្រដ៏សំខាន់ផង គឺប្រភពអក្សរសាស្ត្រនេះហើយដែលបានផ្តល់ពត៌មានឱ្យយើងដឹងពីប្រភពរបស់វត្តអារាមយ៉ាងច្បាស់ ។

### ៣.១. <u>សម័យកាលទី១</u>

សម័យកាលនេះជាសម័យនគរភ្នំពីក្នុងសតវត្សទី១ដល់ទី៦ ។ កាលនោះស្តេចខ្មែរយើងសុទ្ធតែគោរពសាសនាព្រាហ្មណ៍ភាគច្រើន និងព្រះពុទ្ធសាសនាមហាយានខ្លះៗ ព្រោះជនជាតិឥណ្ឌាព្រាហ្មណ៍កោណ្ឌញ្ញដែលបានមកបោះជំរំយ៉ាងសមសួនទៅលើដែនដីគោកធ្លកនេះ សុទ្ធតែជាអ្នកគោរពនិងនិយមសាសនាទាំងពីរនេះ ទាំងអស់គ្នា ។

តាមការសិក្សាស្រាវជ្រាវរបស់អ្នកប្រាជ្ញបារាំងមួយចំនួនដូចជា ៖ លោក Louis FINOT. លោក GEORGE COEDES ជាដើមបានឃើញសិលាចារឹក វ៉ូកាញ់ ខេត្តញ៉ាត្រាង ដែលពីដើមជាអាណាខេត្តខ្មែរ (វៀតណាមខាងត្បូង) គឺជាសិលាចារឹកដែលមានវ័យចំណាស់ជាងគេនៅទឹកដីដែនអាស៊ីអគ្នេយ៍ ។ សិលាចារឹកនេះជាស្នាព្រះហស្តរបស់ព្រះរាជាខ្មែរមួយព្រះអង្គកាលនៅក្នុងសតវត្សទី៣ នៃគ្រិស្តសករាជមានព្រះនាម ព្រះបាទស្រីមារៈ ឬព្រះបាទហ្វាន់ មិន ដែលឯកសារចិនបានថ្វាយព្រះនាមព្រះអង្គតាមទំនូលភាសាចិនថា ជាហ្វាន់ចេម៉ន ។

សិលាចារឹកនេះបានបញ្ជាក់ថាក្នុងរាជស្តេចស្រីមារៈនេះ ប្រទេសខ្មែរកាន់ព្រះពុទ្ធសាសនាមហាយាន ហើយព្រះរាជាបានយកចិត្តទុកដាក់ចំពោះប្រយោជន៍សត្វលោក (ប្រជារាស្ត្រ) ជាខ្លាំង បានធ្វើបុណ្យឱ្យទានដល់ទុរគតជនដោយចិត្តជ្រះថ្លា ហើយបានរៀបចំជាបទបញ្ញាតិទុកឱ្យក្សត្រក្រោយៗប្រតិបត្តិតាមដោយភក្តីធម៌ ។

ចំណែកសិលាចារឹកមួយផ្ទាំងទៀត គឺសិលាចារឹកអ្នកតាដំបងដែក (តាកែវ) សិលាចារឹកនេះហើយដែលបានថ្លែងពីមហេសីស្តេចកៅណ្ឌិន្យជ័យវរ្ម័ន ឈ្មោះនាងកុលប្រភាវតី ទ្រង់បានជ្រះថ្លាចំពោះសាសនាព្រាហ្មណ៍ហើយបានកសាងទេវដ្ឋាន (ព្រះវិហារ) ដំកល់បដិមាព្រះវិស្ណុ ធ្វើអំពីមាសសុទ្ធ និងសាងសង់លំនៅឋាន វត្តនិងជីកស្រះសំរាប់ពួកព្រាហ្មណ៍ ។



www.budinst.gov.kh www.elibraryofcambodia.org

សិលាចារឹកទាំងអស់នេះបានបង្ហាញឲ្យយើងបានឃើញ និងដឹងថា ប្រាសាទវត្តនៅ ព្រះវិហារ វត្តឯក កើតមានតាំងពីសម័យនោះម្ល៉េះ ប៉ុន្តែវត្តឬវិហារទាំងនោះសាងសង់ឡើងសំរាប់ ឧទ្ទិសដល់សាសនាព្រាហ្មណ៍គឺសំរាប់ថ្វាយព្រះសោយ អាហារ ប៉ុណ្ណោះ ។

### ៣.២.<u>សម័យកាលទី២</u>

សម័យកាលនេះជាសម័យកាលមុនអង្គរ (៥៥០-៨០២) បានបង្ហាញឲ្យឃើញផងដែរនូវ សិលាចារឹកសំខាន់ៗជាច្រើនដូចជា: សិលាចារឹកសំបូរព្រៃគុក (ក្នុងដែនឥសានបុរៈខេត្តកំពង់ធំ) សិលាចារឹកនេះបានបញ្ជាក់ថាខ្មែរយើងកាន់ព្រាហ្មណ៍សាសនានិងព្រះពុទ្ធសាសនា ក៏មានឥទ្ធិពល ខ្លាំងក្លាណាស់ដែរ ។ លើសពីនេះសិលាចារឹកបានបញ្ជាក់ពីរូបសម្ផស្សសោភ័ណភាពខាងរូបរាងកាយ រិទ្ធិអំណាចនិងជំនឿរបស់ស្ដេចឥសានវរ្ម័ន និងស្ដេចមហេន្ទ្រវរ្ម័ន ។ ស្ដេចទាំងអស់អង្គនេះបានកសាង រាជទេវស្ថានសំរាប់ដាក់រូបសំណាក (ទេវរូបនិងពុទ្ធរូប) ទុកជាទីសក្ការៈគោរពបូជា ។ សិលាចារឹកមួយ ទៀតដែលមានសារៈសំខាន់ គឺសិលាចារឹកនៅវត្តព្រៃវែង ស្រុកកំពង់ត្របែកខេត្តព្រៃវែងក្នុងគ.ស.- ៦៦៤ រាជស្ដេចជ័យវរ្ម័នទី១ ។សិលាចារឹកនេះបានបង្ហាញឲ្យដឹងថា សម័យនោះខ្មែរកាន់សាសនា ព្រះពុទ្ធដែលមានភិក្ខុសង្ឃកាន់ក្រឹត្យវិន័យបានយ៉ាងត្រឹមត្រូវ ហើយមានក្សត្រស្ដេចចូលមកបួសផងដែរ ចំណែកឯការទំនុកបំរុងនៅក្នុងវត្តអារាម គឺធ្លាក់ទៅលើស្ដេចជាអ្នកអាណាព្យាបាល ។

សិលាចារឹកទាំងអស់នេះ បានបង្ហាញឲ្យយើងដឹងថា ការកសាងវត្តអារាម មានតាំងពី យូរយារណាស់មកហើយគឺចាប់តាំងពីមានព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនាហូរចូលមកក្នុង ស្រុកខ្មែរយើងមកម្ល៉េះ ។



www.budinst.gov.kh www.elibraryofcambodia.org

## ៤.ការពន្យល់ពាក្យខ្លះៗ

ដើម្បីជាមូលដ្ឋានការសិក្សាអំពីវត្តអារាម ជាដំបូងយើងត្រូវស្វែងយល់ពីពាក្យខ្លះៗ ដែលទាក់ទងការប្រើប្រាស់នៅក្នុងបរិវេណវត្តអារាមជាមុនសិនជាស្ពានចំលងអោយ យើងទៅដល់ទីវត្តអារាម។

-វត្ត (វត > វាត់,ពាត់)

ពាក្យ"វត្ត"នេះ កាលពីដំបូងជាកិរិយាស័ព្ទ(តាមសិលាចារឹក) គឺសរសេរ: វត (កិ) មានន័យថា ធ្វើរបងពីភូមិ ឬ បរិវេណសំរាប់ធ្វើកន្លែងពាំងទី។

<u>ឧទាហរណ៍</u>: វតរបងសំរាប់ទុកជាទីភូមិ។

ពេលក្រោយមកទើបពាក្យ"វត្ត" នេះក្លាយទៅជានាមវិញ គឺសរសេរ: វត្ត (ន) មានន័យ ថាទីឋាន ឬបរិវេណសំរាប់ទុកប្រណិបត្តិ។

<u>ឧទាហរណ៍១</u>:អោយកូនទៅវត្ត បានន័យថាអោយកូនទៅនៅរៀនសូត្រអក្សរវត្ត។

ម្យ៉ាងទៀតពីបុរាណកាលហៅថា "ក្តី" ពុំមែនហៅថាវត្តដូចសព្វថ្ងៃនេះទេ។

<u>ឧទាហរណ៍២</u>: អោយកូនទៅនៅក្តី។

លោកទៀវ បញ្ញាវុឌ្ឍ : តាមខ្ញុំធ្លាប់ដឹងហើយយល់ :

-"វត្ត"=កិច្ចប្រតិបត្តិ, សេចក្តីប្រព្រឹត្ត (>វត +ណ)

-"វាត" (មិនមែន"វត"ទេ)=ពង្រីកឱ្យធំ(ទើបអាចក្លាយជា"ពាត"ជា"ពាត់")

-អារាម(សំ-បា):មានន័យថា ជាប្រទេសឬកន្លែងដែលនាំទឹកចិត្តអោយសប្បាយរីករាយ ដូច: ជាសួនឧទ្យានជាដើមដែលអាចយោងចិត្តបរិសុទ្ធរីករាយរបស់ពួកបព្វជិត។

ខ្មែរយើងតែងហៅចំពោះទីវត្តរបស់បព្វជិតថា អារាមឬវត្តអារាម។ទីវត្តបានជាគេហៅអារាម ព្រោះកាលពីក្នុងសម័យបុរាណព្រះទាយកគេច្រើនយកសួនឧទ្យាន ឬឧទ្យានធ្វើជាទីអាវាសសំរាប់ពួកបព្វជិត ដូចយ៉ាងដូចជា:វត្តវេឡុវ័ន ក្នុងពុទ្ធកាលជាដើម។ លើសពីនេះនៅក្នុងទីធ្លាវត្តទាំងមូលទាំងពួង គេដាំដើមឈើតូចធំមានរបៀបជាសួនឧទ្យាន ដែលជាទីសប្បាយរីករាយជាភូមិលំនៅឋាន របស់ពួកគ្រហស្ថ។ហេតុនេះហើយទើបហៅថា: អារាម មានន័យស្មើនឹងសួនឧទ្យាន។

- អារាមវត្ថុ គឺជារបស់របរទាំងពួងណាដែលមាននៅក្នុងបរិវេណវត្ត។
- អារាមរោបកម្ម គឺការដាំសួនច្បារ ឬសិល្បៈខាងដាំសួនច្បារ។



www.budinst.gov.kh www.elibraryofcambodia.org

- អារាមាធិការជា ចៅអធិការវត្តហៅអារាមាធិការក៏បាន

ឧទាហរណ៍ : អារាមាធិការក្នុងវត្តនេះចេះធម៌អាថ៌ច្រើនចេះគ្រប់គ្រងមើលត្រួតតាមទំនងនាយកធម៌ទាំងព្រំមួយ។ បើខ្វះធម៌នៅក្នុងខ្លួន ច្រើនមុខហួងអោយព្រួយ ឥតមានអ្នកណាជួយទេ ត្រូវចេះជួយខ្លួនឯង។

-អារាមិក (អារាមិកៈ) ជាអ្នកកាន់កាប់ឬអ្នកថែរក្សាសួនអ្នកទំនុកបំរុង ផ្គត់ផ្គង់វត្ត (ឈ្មោះវត្តបើស្ត្រីជាអារាមិកា) ។នៅក្នុងបុរាណសម័យ អារាមិក ឬអារាមិកា គឺសំដៅទៅលើ ឧបាសក ឧបាសិកា អ្នកទទួលទំនុកបំរុងវត្ត។

លោក ខៀវ បញ្ញាវុឌ្ឍៈ បើខ្ញុំធ្លាប់ដឹងហើយយល់ :

-"អារាម"=កន្លែងជាទីត្រេកអរ (ក៏ជាសួនហើយប៉ុន្តែ)ដែលសំខាន់នោះគឺទីគោរព ប្រព្រឹត្ត ប្រតិបត្តិ (ដែលជាគំនិតរបស់ចាស់ទុំគ្រប់ជំនាន់ រឹងឈ័យថា"សួន" សម្រាប់ទាក់ទាញចិត្តឱ្យចង់ចូលគោរពប្រតិបត្តិ ឬសរៀនតែប៉ុណ្ណោះ ។

-ចេតិយ < ចេត្យា (សំ):ជាកន្លែងសំរាប់គោរពបូជា និងតំកល់ព្រះពុទ្ធអង្គ។ ប៉ុន្តែសព្វថ្ងៃនេះជនជាតិខ្មែរស្គាល់ថាចេតិយគឺសំរាប់ដាក់ឆ្អឹងខ្មោចទៅវិញ ដោយពួកគេយល់ថាយកបុគ្គលដែលស្លាប់ទៅនោះធ្វើជាមួយព្រះ ដើម្បីអោយវិញ្ញាណនោះបានទៅដល់ឋានសួគ៌ផងដែរ។

-សាលា (សំ): ជាកន្លែងសំរាប់ទទួលប្រជុំធ្វើបុណ្យទានផ្សេងៗនៅបរិវេណទីវត្តអារាម។ ពាក្យសាលានេះគឺមាន : សាលាឆាន់, សាលារៀន, សាលាបាលី(សាលាពុទ្ធិកសិក្សា) និង សាលាឆទាន ។ ចំពោះសាលាឆទាន គឺជាប្រភេទសាលាមួយសំរាប់ដាក់ទានដល់ទុរគតជនទាំងឡាយដែលបានមកដល់ទីវត្តផងដែរ។ សាលាឆទាននេះទាំងអស់មានចំនួន៦(ប្រាំមួយ) ដោយការកសាងឡើងនៅក្នុងបរិវេណទីវត្តចំនួនពីរសាលា និងចំនួន ៤ សាលាទៀតសង់នៅផ្នែកខាងក្រៅរបងទីវត្តអារាម ។

-វិហារ < វិហារ (សំ): ជាបរិវេណទីវត្តអារាមទាំងមូល។ (តាមសិលាចារឹក)

-វិហារកម្មគឺជាការកសាងវត្ត ឬការធ្វើព្រះវិហារ ។

-វិហារបាលគឺជាអ្នកថែរក្សាទីវត្ត សំដៅទៅលើមនុស្សប្រុស ។

-វិហារបាលិនីគឺជាអ្នកថែរក្សាទីវត្ត(ដូនជី ឬយាយជី)។

-វិហារភ័ណ្ឌ ជាកុដិ សាលា ដែលជារបស់សំរាប់វត្ត ទ្រព្យសម្ប។

-វិហារមហាកម្មជាពិធីបុណ្យឆ្លងវត្ត ឬបុណ្យឆ្លងព្រះវិហារ ។

-វិហារវត្ថុ ជារបស់របរផ្សេងៗទាំងអស់ដែលនៅក្នុងបរិវេណវត្តរួមទាំងដើមឈើ សួនដំណាំជាដើម។



www.budinst.gov.kh www.elibraryofcambodia.org

-កុដិ (សំ) ជាខ្ទម ផ្ទះតូចៗសំរាប់ជាលំនៅឋានរបស់អ្នកបួស ។

-ឧបដ្ឋានសាលា (ខ): ជាសំណង់ធំៗជាសាលាសំរាប់ប្រើប្រាស់ក្នុងវត្តអារាមហៅសាលាបុណ្យ។

-ជើងវត្ត (ខ): ក្រុមមនុស្សដែលស្ថិតនៅជុំវិញទីវត្ត ហើយជួយទំនុកបំរុងផ្គត់ផ្គង់វត្តអារាម។

-ស្រះ < សរស (សំ): ទីដាក់ទឹកធំដែលកើតឡើងពីការជីកយកដីទៅចាក់បំពេញទីទំនាបក្នុងវត្ត ឬចាក់បំពេញខឿនព្រះវិហារ ។

តាមកំណើតរបស់ពាក្យគឺសរសេរ "សរស" ពីព្រោះក្លាយមកពីពាក្យសំស្ក្រឹត ប៉ុន្តែដោយធ្លាប់ប្រើសរសេរជា "ស្រះ" នេះយូរអង្វែងមកហើយដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

## ៥. ជំនឿនិងទំលាប់នៃក្បួនខ្នាតខ្លះៗ

តាមការចុះសិក្សាស្រាវជ្រាវផង និងសាកសួរពីលោកតាអាចារ្យនៅតាមវត្ត ដែលមានវ័យចំណាស់ៗផងហើយរួមពីសំណាក់លោកគ្រូខាងផ្នែកសំណង់ខ្មែរបុរាណផងនោះ នាំអោយខ្ញុំទទួលបានលទ្ធផលដូចខាងក្រោមទាំងអស់នេះ ។

### ៥-១- ការតាំងទីថ្មី

តាមទំលាប់របស់ចាស់បុរាណ បានបន្សល់និងបន្តរហូតដល់ចាស់ៗសម័យឥឡូវនេះ ប្រើប្រាស់ក្បួនជ្រើសរើសទីតាំងថ្មីតាមរបៀបចាស់ៗ ។ ទំលាប់ទាំងអស់នេះគឺ មុននិងចាប់ផ្តើមសាងសង់សំណង់អ្វីមួយ មិនថាជាសំណង់លំនៅដ្ឋាន ឬសំណង់បំរើសាសនាទេ នៅលើទីកន្លែងណាមួយនោះ គាត់បាននាំអោយហោរាទស្សទាយ គន់គូរមើលអំពីទីដីដែលបំរុងនិងជ្រើសយកសំរាប់តាំងទីថាតើត្រូវសង់កន្លែងណា? ហើយបែរមុខសំណង់ទៅទិសខាងណា? ដំណើរនេះប្រយោជន៍អោយមនុស្សរួលនៅរស់នៅទីនោះប្រកបដោយសេចក្តីសុខសប្បាយ ។ ម្យ៉ាងទៀតចំពោះការជ្រើសរើសទីដីសំរាប់សាងសង់វត្តអារាមថ្មីគឺចាស់ៗគាត់មើលយកទីណាដែលខ្ពស់ជាងគេ កុំអោយលិចទឹកទៀតផង ។ នៅវេលាយប់ស្ងាត់ខែភ្លឺគាត់បាននាំគ្នា៣-៤នាក់ចាស់ៗក្នុងភូមិទៅអង្គុយមើលដើមឈើណាមួយដែលធំជាងគេនៅលើដីទួលដែលបានជ្រើសរើសទុករួចនោះ ហើយប្រៀបប្រដូចដើមឈើនោះទៅនិងសព្វផ្សេងៗ ហើយពិគ្រោះគ្នាសន្និដ្ឋានថា :

- ប្រសិនបើការសង្កេតមើលដើមឈើនោះទៅឃើញសណ្ឋានជារូបរាងដូចសត្វខ្លានោះទំនាយថាមិនល្អទេ គឺមានព្រាយបិសាច កើតមានចោរកម្មមកបៀតបៀន ធ្វើអោយកើតមានគ្រោះមហន្តរាយ ឬធ្វើទុក្ខបុកម្នេញ ដល់អ្នកស្រុកភូមិដែលតាំងទីនៅជិតទីវត្តនោះដែរ ចៀសវាងពុំផុតឡើយ ។

- ប្រសិនបើមើលទៅដើមឈើនោះជារូបរាងមានសណ្ឋានដូចដំរីវិញ ទំនាយថាល្អណាស់ ពេលសាងសង់វត្តនៅលើបរិវេណដីដែលជ្រើសរើសនោះនិងផ្តល់នូវភាពត្រជាក់ត្រជុំ សុខចំរើនដល់អ្នកស្រុកផងទាំងពួង ។

### ៥-២- ការរៀបចំសំណង់ក្នុងទីវត្ត

ទំហំដីដែលគេកំណត់សំរាប់ធ្វើបរិវេណវត្តគឺ ២៥០ម៉ែត្រ និង ១៥០ម៉ែត្រដោយគិតយកបណ្តោយត្រង់ដែលវែងពីទិសខាងលិចទៅខាងកើតហើយទទឹងត្រង់ខ្លីពីទិសខាងជើងទៅខាងត្បូង ។ ទិសសំរាប់សាងសង់ព្រះវិហារគឺកំណត់យកពីអ័ក្សចំកណ្តាលទៅទិសខាងកើត (មើលប្លង់ទី២)



www.budinst.gov.kh www.elibraryofcambodia.org

ទិសឦសាន សំរាប់សាងសង់ទីមន្ទីរនិងធ្វើចេតិយ ទិសឧត្តរសង់បន្ទប់អនាម័យ និងសង់ផ្ទះបាយ ទិសពាយ័ព្យសង់សាលាបិណ្ឌ សាលាឆាន់ និងធ្វើអាស្រមសំរាប់ជូនជីសំណាក់ធំ ទិសបច្ចិមសង់កុដិទោរអធិការវត្តនិងអមដោយកុដិគ្រូសូត្រស្តាំ ទិសនិរតីសាងសង់សាលាពុទ្ធិកៈនិងសាលាបាលី ទិសទក្សិណសង់បណ្ណាល័យ និងសាលារៀន ពីទិសអគ្នេយ៍ទៅទិសបូព៌សំរាប់ធ្វើរមណីដ្ឋានរបស់ពុទ្ធសាសនា និងគួរចាំបាច់នៅទិសអគ្នេយ៍មានធ្វើរោងដាក់ទូកមួយផង ។

"មើលរូបប្លង់ទីតាំង"

៥-៣-. <u>ការប្រើប្រាស់ពណ៌</u>

នៅលើសំណង់ទាំងឡាយនៅក្នុងវត្តអារាម គុបតែងលំអទៅដោយក្បូរក្បាច់របចនាស្លឹកស្លះ លើសពីនេះបានបន្ថែមលាបពណ៌ចំរុះឡាយល្អំផ្ទាទាំងផ្នែកខាងក្នុងនិងផ្នែកខាងក្រៅនៃអាគារ ទៅតាមការរៀបចំអោយមានសោភ័ណភាពផង និងមានអត្ថន័យខ្លឹមសារខាងសាសនាផងដែរ ។

សំណង់ព្រះវិហារជាសំណង់មួយដែលការសាងសង់ឡើងត្រូវបានគេយកចិត្តទុកដាក់ ជាងសំណង់ផ្សេងៗទៀត នៅក្នុងបរិវេណទីវត្តដូចគ្នា គឺគិតលំអិតតាំងពីខ្នាត, ក្បាច់បំពាក់, ពណ៌ចាប់តាំងពីចំបូលរហូតដល់ជើងជាន់ជាប់និងដី ។ ដូច្នេះព្រះវិហារជាសំណង់មួយដែលមានចំណាប់អារម្មណ៍ជាងគេនៅក្នុងចំនោមសំណង់ទាំងឡាយដែលសង់នៅក្នុងបរិវេណទីវត្តអារាម ។

ការសិក្សាពីពណ៌មានសារៈប្រយោជន៍ល្អណាស់ ផ្តល់អោយយល់ដឹងពីរបៀបប្រើពណ៌ ការផលិតពណ៌យកពីរុក្ខជាតិ និងអត្ថន័យរបស់ពណ៌ ។នៅទីវត្តកាលពីបុរាណដូនតាយើង បានយកពណ៌ដើម (ពណ៌មេ)គឺពណ៌ក្រហម លឿង ខ្មៅ និងខៀវ ទៅលាយដាក់បញ្ចូលគ្នាបង្កើតបានជាពណ៌ផ្សេងៗតាមចិត្តត្រូវការ ។ ពណ៌ដើមទាំង៤មុខនេះគាត់ (ដូនតា)បានចំរាញ់យកពីរុក្ខជាតិមួយចំនួនមកប្រើប្រាស់តាមតំរូវការរបស់ពួកគាត់ ដូចជាពណ៌លឿងចំរាញ់ចេញពីល្មៀត និងដើមក្រមូង ពណ៌ខៀវចំរាញ់ចេញពីស្លឹកបាស និងត្រួយស្តៅ ពណ៌ខ្មៅចំរាញ់ចេញពីម្រ័ក្ស ហើយនិងពណ៌ក្រហមចំរាញ់ចេញពីដើមថ្នង់និងជំពូស្រដោយយកផ្លែនិងសំបកដើមរបស់វា ។ដូច្នេះមនុស្សខ្មែរជំនាន់កាលនោះ មានប្រាជ្ញា-ស្មារតី ច្នៃប្រឌិតធម្មជាតិមកប្រើការបានប្រយោជន៍ដល់សង្គមជាតិទូទៅ ដោយគ្មានត់និតបំផ្លាញល្បាទីសត្វ ពោងប្រវ័ញ្ចពីគ្នានិងគ្នា ។ល ។

ចំណែកឯបច្ចេកទេសលាយពណ៌វិញ គឺយកជ័រដុងបុកបំបែកអោយហ្មត់ដាក់លាយជាមួយជ័រទឹកអោយចូលគ្នាជាមុនសិន រួចហើយទើបយកពណ៌ដែលទៀតមកដាក់លាយបញ្ចូលជាមួយតំរូវទៅតាមចិត្តចង់បានពណ៌យកមកប្រើ ។



www.budinst.gov.kh www.elibraryofcambodia.org

វិធីលាយពណ៌នេះមានគុណភាពល្អអាចរក្សាពណ៌បានយូរ មិនងាយហើរពណ៌ លើសពីនេះទៀតអាចធន់ទ្រាំនឹងអាកាសធាតុស្រុកយើងទៀតផងដូចជា : ទឹកភ្លៀង និងកំដៅថ្ងៃជាដើម ។

ពណ៌មាសជាពណ៌មួយដែលមានប្រជាប្រិយភាពក្នុងការយកមកប្រើប្រាស់ច្រើនជាងគេនៅទីវត្ត ដោយហេតុថា : ពណ៌មាសនេះជាពណ៌ថ្លៃថ្នូរ មិនឈ្លើយ អាចដាក់ជាមួយ (ស៊ីគ្នា) ពណ៌ក្រហម ពណ៌បៃតងចាស់ ពណ៌ខៀវចាស់ ពណ៌ឈាមជ្រូក ។ល។ ដែលអាចធ្វើឱ្យភ្នែកយើងមើលទៅឃើញពណ៌ស្រស់ ហើយសោភ័ណភាពល្អប្រណិត ។ ប៉ុន្តែការប្រើប្រាស់ពណ៌នៅក្នុងទីវត្ត មិនអាចអនុញ្ញាតឱ្យប្រើពណ៌ផ្លេសផ្លាស ឬឆើតឆាយ ធ្វើឱ្យអារម្មណ៍ភ្លើតភ្លើន ស្រើបស្រាលនោះទេ គឺសិក្សាប្រើប្រាស់ពណ៌ទាំងឡាយណាដែលនាំឱ្យចិត្តមនុស្សគ្រប់ៗរូបចូលដល់ទីវត្តមានសភាព ស្ងប់ស្ងៀម ល្អូតល្អត និងបរិសុទ្ធ ដើម្បីប្រមូលអារម្មណ៍ខ្វល់ខ្វាយផ្សេងៗ តាមការបំណងប្រាថ្នារៀងៗខ្លួន ។ ពណ៌ដែលយកមកប្រើភាគច្រើននៅទីវត្ត គឺ ពណ៌លឿង ពណ៌មាស និងពណ៌ស ជាដើម ។

<u>អត្ថន័យរបស់ពណ៌នីមួយៗ</u> :

-ពណ៌ស (គុណម្តាយ) គឺជាពណ៌ស្អាតស្អំបរិសុទ្ធ

-ពណ៌ខៀវ (គុណឪពុក) គឺជាពណ៌ស្មោះត្រង់គ្មានព្រំដែន

-ពណ៌លឿង (គុណបងប្អូននិងអ្នកគ្រប់គ្រងរដ្ឋ) ជាពណ៌ប្រាជ្ញា ផ្សរផង់ បញ្ញា និងពុទ្ធិ

-ពណ៌បៃតង ជាពណ៌ចំរើនលូតលាស់ និងការសង្ឃឹម

-ពណ៌ក្រហម ជាពណ៌អង់អាចក្លាហាន ប្តូរផ្តាច់

<u>តំណាងរបស់ពណ៌នីមួយៗ</u> :

-ពណ៌សតំណាងឱ្យធាតុទឹក

-ពណ៌លឿងតំណាងឱ្យធាតុខ្យល់

-ពណ៌បៃតងតំណាងឱ្យធាតុដី

-ពណ៌ក្រហមតំណាងឱ្យធាតុភ្លើង

សរុបសេចក្តីមក ការប្រើប្រាស់ពណ៌នៅក្នុងទីវត្តអារាម សំរាប់លំអរ និងបង្កើនសោភ័ណភាព ដែលអាចទាក់ទាញចិត្តមនុស្សឱ្យនៅចូលទស្សនា សិក្សា និងធ្វើពិធីគោរពបូជាផ្សេងៗ នៅតាមទំនៀមទំលាប់ប្រពៃណីរបស់ជាតិយើង ។



www.budinst.gov.kh www.elibraryofcambodia.org

## ៤.៤. <u>ព្រះវិហារ</u>

នៅក្នុងទីវត្តសំណង់ដែលមានទ្រង់ទ្រាយធំ ហើយយកចិត្តទុកដាក់ជាងគេគឺសំណង់ព្រះវិហារ ព្រោះថាព្រះវិហារជាសំណង់មួយមានតួនាទីសំខាន់ជាងគេក្នុងបរិវេណវត្តអារាម ។ ការសាងសង់សំណង់ព្រះវិហារ គឺបំរើឱ្យពុទ្ធបូជាហើយដំកល់បដិមាព្រះពុទ្ធរូបនៅក្នុងនោះ ។ តាមតួនាទីរបស់សំណង់ព្រះវិហារនេះសន្និដ្ឋានបានថា : ព្រះវិហារស្មើនឹងចេតិយ៍ដែរ (មើលពន្យល់ពាក្យចេតិយ៍)

| |
|---|
| ព្រះវិហារ = ចេតិយ៍ (ដំកល់ព្រះពុទ្ធបដិមា) |

### *៤.៤.១.<u>ការបែរទិស</u>*

ហេតុអ្វីបានជាគេសង់ព្រះវិហារបែរមុខទៅទិសខាងកើត ?

ជាទូទៅព្រះវិហារទាំងអស់គេនិយមសង់បែរផ្នែកខាងមុខព្រះវិហារទៅរកទិសខាងកើត មកពីមានទំនាក់ទំនងជាមួយព្រះពុទ្ធរូប ។

ហេតុអ្វីបានជាព្រះអង្គជាម្ចាស់បែរព្រះភក្ត្រទៅទិសខាងកើត ?

ការបែរព្រះភក្ត្រទៅទិសខាងកើតនោះ មានការដំណាលតៗគ្នាអំពីការគង់សុក្រុមភាវនាធម៌របស់ព្រះអង្គម្ចាស់នៅក្រោមម្លប់ដើមពោធិព្រឹក្សមួយ ។ ដំណើររឿងនេះមានដូចតទៅ : ជាកិច្ចចាប់ផ្ដើមដំបូងឡើង ព្រះអង្គបានគង់បែរព្រះភក្ត្រទៅរកទិសខាងលិច រួចហើយលើកហត្ថប្រណមឡើងសុក្រម ទ្រង់ព្រះនេត្រទៅឃើញថាមិនបានសុខស្រួលក្នុងព្រះកាយសោះ ដោយមានវិបផលដូចនេះព្រះអង្គបានប្ដូរទីតាំងបែររកទិសខាងជើងវិញ ហើយក៏នៅតែមិនមានភាពសុខស្រួលដដែល ព្រះអង្គបានប្ដូរទីតាំងបន្តទៀត ដោយគង់បែរទៅរកទិសខាងត្បូងម្ដង ក៏ប៉ុន្តែនៅតែមិនទាន់បានទទួលនូវភាពសុខស្រួលក្នុងអង្គកាយទៀត ។ ម្ដងនេះជាទិសចុងក្រោយបង្អស់របស់ ទិសទាំងបួន គឺព្រះជាអង្គម្ចាស់បែរព្រះភក្ត្រទៅរកទិសខាងកើតនេះឯង ពេលព្រះអង្គលើក ហត្ថសុក្រុមភាវនានៅ ឃើញថា បានទទួលអារម្មណ៍ស្ងប់ស្ងាត់ មានភាពសុខស្រួលក្នុងអង្គកាយ ហើយទទួលបានផលសំរេចពីការភាវនាធម៌របស់ព្រះអង្គគ្រប់ប្រការទាំងអស់ ។

តាមការសំអាងលើហេតុផលដូចរៀបរាប់ខាងលើនេះ ទើបទំលាប់តាមកសាងសង់ ព្រះវិហារបែរមុខទៅរកទិសខាងកើត ។

ប៉ុន្តែសម័យបច្ចុប្បន្នយើងនេះ ការសាងសង់ព្រះវិហារគឺអាស្រ័យទៅលើស្ថានភាពទីតាំងភូមិសាស្ត្រនៅទីកន្លែងនោះផ្ទាល់ ដោយពុំមែនចាំបាច់ត្រូវតែសង់បែរមុខទៅរកទិសកើតទាំងអស់ទេ ។



www.budinst.gov.kh www.elibraryofcambodia.org

### ៤.៤.២.ខឿន (ទី១-២-៣)

ខឿនមានន័យថា : ជាថ្នាក់ ជាន់រងគេហដ្ឋាន ឬទីដែលលើកហើយមានព្រះកូនឈើ (កូនឈើមូលៗ ) ជុំនកាលរៀបឥដ្ឋ ឬថ្មរាំងពីខាងជុំវិញ ដើម្បីការពារមិនឱ្យរិចរឹល ។

ឧទាហរណ៍ : ខឿនប្រាសាទ ខឿនព្រះវិហារ ជាដើម។

តាំងពីបុរាណមក ជាទំនៀមទំលាប់ប្រពៃណី ហើយក៏ជាក្បួនខ្នាតដែលបុព្វបុរស ឬក៏អ្នកទេះៗជំនាន់នោះ បានសិក្សាល់អិត ឱ្យសុក្រឹត្យបំផុតផងដែរ គឺប្រាសាទ ឬព្រះវិហារ ត្រូវបានសាងសង់ឡើងនៅលើខឿនជានិច្ច នៅតាមលទ្ធភាពរបស់អ្នកកសាង (និយាយសំដៅលើបច្ច័យសំរាប់សាងសង់) ប៉ុន្តែមិនអាចអនុញ្ញាតិអោយសង់ខឿនលើសពីបីថ្នាក់ឡើយ (ជាន់) ។ចំពោះការរាប់ជាន់ឬថ្នាក់នេះ គឺគិតរាប់ថាជាន់ទី១ជាតួរបស់ព្រះវិហារ ហើយជាន់ទី២និងជាន់ទី៣ គឺរាប់បន្តចុះមករកបន្ទាត់ផ្ទាល់ដី ។ (មើលរូប)




-ខឿនទី១ (តួព្រះវិហារ)

ខឿនទី១ជាខឿនសំខាន់ជាងគេ ព្រោះជាតួរបស់ព្រះវិហារដែលចាំបាច់ត្រូវមានក្បួនខ្នាតយ៉ាងច្បាស់លាស់ មានដូចខាងក្រោមនេះ :



www.budinst.gov.kh www.elibraryofcambodia.org

- ប្រវែងទទឹងព្រះវិហារ ស្មើនឹងផលបូកប្រវែងរួមគ្នាគឺយកថ្នឹមបូកពីរដងរបៀងនឹងបូកពីរដង ជាំងសាចបញ្ចូលគ្នា ។

| ទទឹងព្រះវិហារ = ថ្នឹម + ២របៀង + ២ជាំងសាច |
|---|

ឬ

| ទទឹងព្រះវិហារ = ថ្នឹម + ២(របៀង + ជាំងសាច) |
|---|

- ប្រវែងបណ្តោយព្រះវិហារស្មើនឹងប្រវែងទទឹងព្រះវិហារគុណនឹង២ មានន័យថា២ដងទទឹង

| បណ្តោយព្រះវិហារ = ទទឹងព្រះវិហារ × ២ |
|---|

- ប្រវែងថ្នឹមរបស់ព្រះវិហារគឺគេកំណត់យកទៅតាមចិត្តចង់បាន ប្រសិនបើតំរូវការកន្លែងណោកស្បូតធំច្រើននោះ គេយកកំណត់សសរពីមួយទៅមួយធំ ហើយនឹងថយមកវិញ។ ប៉ុន្តែមិនត្រូវភ្លេចពីរចនាសម្ព័ន្ធរបស់សំណង់ឡើយ ។

- កំពស់ព្រះវិហារគិតត្រឹមរនស្សរក្រោមដំបូលស្មើនឹងថ្នឹមគុណនឹងពីរ

| ថ្នឹម × ២ |
|---|

- ប្រវែងរបៀងស្មើនឹងប្រវែងថ្នឹមចែកជា ២

| របៀង = ថ្នឹម : ២ |
|---|

- ប្រវែងជាំងសាចស្មើនឹងប្រវែងរបៀងគុណនឹង២ ហើយយកមកចែកជា ៣ទៀត ។

$$ជាំងសាច = \frac{របៀង \times ២}{៣}$$

-ខឿនទី២

ប្រវែងខឿនទី២ គេកំណត់យកពី ៣ម៉ែត្រទៅ៥ ម៉ែត្រ

-ខឿនទី៣

ប្រវែងខឿនទី៣ គេកំណត់យកពី ៥ម៉ែត្រ ទៅ ៧ម៉ែត្រ

ការកំណត់យកខឿនទី២ និងទី៣ នេះគឺអាស្រ័យទៅលើចំណោះភូមិរបស់វត្តផងដែរ ។ ប្រសិនបើវត្តមានឡូកស្រុកចំណោះធំ វត្តច្រើននោះគេកំណត់យកខ្នាតធំ និងត្រលប់ថយមកវិញ ។

-កំពស់ខឿន



www.budinst.gov.kh www.elibraryofcambodia.org

ចំពោះកំពស់របស់ជឿងនីមួយៗគឺកំណត់ទៅតាមកំពស់ចំនួនកាំជណ្ដើរសេស គឺ ៣-៥-៧-៩ ។ល។ ម្យ៉ាងទៀតគឺអាស្រ័យទៅតាមទីតាំងនភូមិសាស្ត្រផងដែរ ។






www.budinst.gov.kh www.elibraryofcambodia.org

### ៥.៤.៣ សសរ

ជាទូទៅនៅតាមប្រាសាទក៏ដូចជាព្រះវិហារដែរ ជួនកាលគេធ្វើសសរមូល និងសសរជ្រុង តាមតួនាទី ឬតាមចិត្តស្រឡាញ់ ។ សសរមានតួនាទីសំខាន់ណាស់នៅក្នុងវេចនាសម្ព័ន្ធ របស់សំណង់គឺអាចទប់ និងអាចទ្រទំងន់អាគារទាំងមូលឱ្យឈរស្ងៀមស្ងាត់បាន ម្យ៉ាងទៀតសសរក៏ជាគ្រឿងលំអរ សោភ័ណ្ឌភាពរបស់សំណង់ផងដែរ ។

សសរមាន៣ប្រភេទគឺ :

-សសរកន្លោង គឺជាសសរកណ្ដាល ជាមេលើសសរអស់ទាំងពួង

-សសរជើងវៀង ជាសសរជួរខាង

-សសរស្ដម ជាសសរបណ្ដោះបន្តុបពីលើថ្នឹម ទ្រទាប់គ្រឿងល្វែងចាំងសាច ។

ចំពោះសសរព្រះវិហារ ឬប្រាសាទ សសរមួយដើមចែកចេញជា ៣ផ្នែក គឺជើងសសរ តួសសរ និងក្បាលសសរ។ សសរទាំងមូលត្រូវបានគេលំអទៅដោយក្បូរក្បាច់រចនាតាំងពី ជើងសសររហូតដល់ក្បាលសសរ។ លើសពីនេះទៅទៀត មានបំពាក់វៃរាំមួយឬ ពីរ (តាមតួនាទី) បន្ថែមធ្វើឱ្យលើកសំរស់សសរមួយកំរិតទៀត។ នៅលើក្បាលសសរគេឆ្លាក់ : ត្រទាប់ហៀនឈូក, ល័ហួត, វិជ្ជាលពេជ្រ, ល័ហួតវិជ្ជាល និងឈូក (រាប់ឈ្មោះពីផ្នែកខាងលើចុះមកក្រោម)។ ចំណែកជើងសសរវិញ គឺគេដាក់ក្បាលសសរត្រលប់ចុះក្រោមវិញ ប៉ុន្តែគេថែមទ្រនាប់ឱ្យក្រាស់ ជាងក្បាលសសរបន្តិចប៉ុណ្ណោះ ។ (មើលរូប)

**ក្បាលសសរក្បាច់អង្គរ**






www.budinst.gov.kh www.elibraryofcambodia.org

## ជើងសសរក្បាច់អង្គរ



### *៥.៤.៤ ក្រា ផ្ការ៉ា*

នៅលើសំណង់ខ្មែរបុរាណយើង ជាពិសេសសំណង់ព្រះវិហារ គឺគេដាក់បំពាក់លំអរទៅដោយផ្ការ៉ា នៅតាមគ្រប់សសរទាំងអស់សំរាប់ឈរទ្រពីក្រោមចន្ទ្យូលជាគ្រឿងរចនាឱ្យមានសោភ័ណភាពសំណង់មួយកំរិតទៀត ។ ផ្ការ៉ាមានច្រើនប្រភេទដូចជា : កីណាក្រុង ខៃឧទយ, ទេពប្រណម្យ គិន្នរ។ល។ ប៉ុន្តែសំណង់ព្រះវិហារគេយកផ្ការ៉ាតែ៣ប្រភេទមកប្រើប្រាស់គឺ : កីណាក្រុង គេប្រើវាដាក់ទ្រនៅតាមសសរជ្រុងខាងទាំង៤របស់ព្រះវិហារ, រីឯគិន្នរគេប្រើដាក់នៅតាមសសរចំហៀងខាងស្តាំនៃព្រះវិហារ ហើយចំពោះផ្នែកខាងមុខ និងខាងក្រោយព្រះវិហារគេដាក់ទេពប្រណម្យវិញ ។

ការបំពាក់ផ្ការ៉ាលើសសរព្រះវិហារជុំវិញនោះបានបញ្ជាក់ភ្នែកយើងឱ្យមើលទៅឃើញសំណង់ហាក់បីដូចជាស្រាល ដោយសារពពួកផ្ការ៉ាទាំងឡាយនោះបានគាំទ្រលើកទ្រ ជំបូលស្លឹយទៅលើឆ្ពោះឋានត្រៃត្រឹងដែលជាលក្ខណៈសំរាប់តែសំណង់សាសនាប៉ុណ្ណោះ ។ ប្រសិនបើប្រៀបធៀបសំណង់ព្រះវិហារយើងទៅនឹងព្រះវិហារនៅអឺរ៉ុប ឃើញថាលក្ខណៈសាងសង់សំណង់ប៉ារីសាសនារបស់ពួកគេនោះគឺសង់ឡើងខ្ពស់ស្រួចទៅលើដូចគ្នា មានន័យថាឆ្ពោះទៅរកពិភពស្ញប់ស្ងាត់,



www.budinst.gov.kh www.elibraryofcambodia.org

ភាពសុខសាន្តចាកផុតពីកម្មពារវេរាទាំងឡាយ ។ ប៉ុន្តែព្រះវិហារយើងមានលក្ខណៈពិសេសលើសគេ ដោយមានពពួកក្រុមវៃវ៉ាដផ្ញៃផ្គួមទៅជាមួយដោយក្ដីរីករាយ ព្រះផ្ទាំងនិងភាពសុខដុមរមនា ។



ទំនេរ



www.budinst.gov.kh www.elibraryofcambodia.org

ខែននយ









www.budinst.gov.kh www.elibraryofcambodia.org



នែននយ



កិន្នរ



យក្ស



www.budinst.gov.kh www.elibraryofcambodia.org









www.budinst.gov.kh www.elibraryofcambodia.org









www.budinst.gov.kh www.elibraryofcambodia.org

៩.៤.៩ <u>រនស្សូរ</u>

ចំពោះសំណង់ទូទៅគេប្រើប្រាស់រនស្សូរសំរាប់ការពារទឹកភ្លៀងកុំឱ្យសាចទៅប៉ះនឹងឈើផ្ទាង ឬផ្ទាងរយ ឬបង្គង់ ធ្វើឱ្យឆាប់ពុកផុយខូចសំណង់អស់។ ការខូចខាតផ្នែកដំបូលនេះពិបាកក្នុងការ ជួសជុលឡើងវិញណាស់។ ប៉ុន្តែលើសពីនេះទៀត រនស្សូរក៏ជាគ្រឿងសំរាប់លំអផងដែរ ជាពិសេស សំណង់នៅក្នុងបរិវេណទីវត្តអារាម ។

នៅលើរនស្សូរគេចំលាក់ក្បាច់ផ្សេងៗ ដូចជា : ក្បាច់សារាយ ក្បាច់កញ្ច្រឿល បណ្ដើរកូន, ក្បាច់រំដួលពងត្រី, ឬក្បាច់ត្របកឈូកបណ្ដើរកូនជាដើម ។ ចំណែកឯទំហំរបស់ រនស្សូរវិញគេយកទៅតាមសំណង់ធំឬតូច ដោយយកទទឹងមិនលើសពី ២០ស.ម ទៅ៤០ស.ម ឡើយ ហើយបណ្ដោយវិញគេយកតាមចិត្តចង់បានតាមតំរូវការ។



ក្បាច់សារាយ



www.budinst.gov.kh www.elibraryofcambodia.org



ក្របកឈុកហ៊ុង



ក្របកឈុកបណ្ដើរគុណ



www.budinst.gov.kh www.elibraryofcambodia.org

### ៥.៤.៦ ក្បឿង

ក្បឿងជាបន្ទះដីដែលគេធ្វើហើយយកទៅដុតឱ្យឆ្អិនសំរាប់យកទៅប្រក់ទីលំនៅ ដោយមានធ្មើសំរាប់ពាក់ជាប់នឹងដៃរណែងហៅថា "ដោះក្បឿង" ។

ដំបូលព្រះវិហារទាំងមូលគ្របដណ្ដប់ពីលើដោយក្បឿងដីដុត ។ ក្បឿងនេះហៅថា ក្បឿងស្រកាលិញ ឬក្បឿងស្រកាខាត ។ ដែលជាគេហៅក្បឿងស្រកាខាតគឺដោយគេពិនិត្យមើលដំបូល ព្រះវិហារជាខ្នងខាតគ្របដណ្ដប់ទៅដោយស្រកា ចំណែកក្បាលខាតគឺជាផ្កាដែលយើងមើលពីចំហៀង ។

ក្បឿងទាំងអស់ដែលខ្ញុំបានឃើញយកមកប្រើប្រាស់ក្នុងសំណង់ព្រះវិហារគឺយកក្បឿងដែលគេផលិតឡើងក្នុងឡូតែមួយម្នាក់ឯង មិនឱ្យលាយឡំនឹងឡដុតក្បឿងយកទៅប្រើលើសំណង់ផ្សេងទៀតឡើយ ។ ក្បឿងប្រភេទនេះជាបន្ទះស្តើងហើយតូចៗ និងស្រាលមានភាពងាយស្រួលក្នុងការប្រើប្រាស់នៅលើសំណង់អំពីឈើ លើសពីនេះផ្តល់លក្ខណៈងាយស្រួលក្នុងការផ្លាស់ប្តូរ ឬជួសជុលអាគារ ។






www.budinst.gov.kh www.elibraryofcambodia.org

### ៥.៤.៧ នាគ-ចហ្វា

នាគ : នៅក្នុងវិថីវត្តអារាម និយមប្រើនាគក្បាល ៥ជានាគអង្គរ។ នៅជាប់និងដីច្រើនប្រើនាគបើកពការ ដូចជាតាមបង្កាន់ដៃជណ្ដើរ និងអមផ្លូវចូលជាដើម។ ចំណែកនៅផ្នែកខាងលើដំបូលរបស់សំណង់វិញ គឺនៅតាមចំហៀងហោនាគខែងហើយនៅជាប់និងហោជាង ហៅជហ្វាជក្ដារនាគ តែដោយឡែកចំពោះព្រះវិហារដំបូលទី១ ជាប់និងហោជាង ហៅនាគវិលគ ហើយដំបូលទី២ ទី៣ ហៅនាគព្រង់។ នៅលើខ្លួននាគប្រើក្បាច់ក្របកណ្ដុកបណ្ដើរក្នុងផែល ឱ្យឈ្មោះថាបៃរកាមានបញ្ហានវែងស្រួចមើលទៅដូចជារន្ធញរណា ដោយសំគាល់ឬតំណាងអោយជានាគរាជដែលជាសត្វនាគមានឫទ្ធិវិទ្ធ លើសអស់សត្វនាគនានា។ ចំពោះបៃរការនេះនិយមយកចំនួន សេស គឺមានអត្ថន័យជាភាពសុក្រិត សំបូរបរឿងបញ្ញាញាណ ចំរើនល្អតលាស់។ល។ ម្យ៉ាងទៀតចំនួនសេសជាចំនួនលើសនិងមានលំនឹងវៃមាំហើយជាចំនួនខ្ពស់ជាងគេជុំដូចជាលេខប្រាំបួន (៩)។ ចំណែកឯក្បាលនាគក៏និយមយកចំនួនសេសដែរគឺ ៣,៥,៧,និង៩ផងដែរ គឺតំណាងឱ្យសភាវៈមានជីវិត។




ចហ្វា នាគសន្លឹក នាគខែង



www.budinst.gov.kh www.elibraryofcambodia.org

<u>ខ្នាតក្បាលនាគ</u>

-កំពស់ក្បាលនាគយក ៣ខ្នាត (១ខ្នាតយកប្រវែងតាមបិត្តបង់ផន)

-កំពស់ពីចង្កាទៅលើយក ១ខ្នាតកន្លះ (១,៥ខ្នាត)

-កំពស់ពីចង្កា មកកយក ១ខ្នាតកន្លះ (១,៥ខ្នាត)

តាមខ្នាតនេះបានក្បាលនាគខ្ពស់ល្អ ។




ជហ្វា : បើក្រលេកមើលឆ្ងាយនោះនឹងឃើញជហ្វាមានសណ្ឋានដូចជាកន្ទុយពស់ កំពុងបក់រស់រវើកនៅលើដំបូលព្រះវិហារ ។ ប៉ុន្តែបើសិននេះពិនិត្យសម្លឹងឱ្យគ្រប់ជ្រុងជ្រោយពីរូបរាង និងទំរង់របស់វានៅមើលដឹងថា វាជាក្បាលនាគមើលទំពីទំហៀងដែលពាក់កណ្ដឹងបញ្ចេញសំលេង យ៉ាងពីរោះនៅតាមកំលាំងខ្យល់បក់ ។

តើហេតុអ្វីបានជាទំនៀមទំលាប់យកនាគ-ជហ្វាដែលជាសត្វកាចសាហាវ (អសិរពិស) មកដាក់នៅលើដំបូលសំណង់ក្នុងទីវត្ត ?



www.budinst.gov.kh www.elibraryofcambodia.org

មូលហេតុបានជាយកនាគ-ជហ្វាមកធ្វើជាគ្រឿងបំពាក់លើសំណង់ក្នុងទីវត្តដែលជាកន្លែងគោរពបូជាដល់ព្រះជាអង្គម្ចាស់នោះគឺមានហេតុផលដូចតទៅ :

ក្នុងខណៈពេលមួយនោះមានភ្លៀងផង ខ្យល់ផង, ព្យុះផង អស់រយៈពេល ៧យប់៧ថ្ងៃ ហើយព្រះអង្គគង់ក្រោមម្លប់ដើមពោធិ៍។ ពេលនោះសត្វនាគក៏មកយកខ្លួនធ្វើជា បល្ល័ង្កឱ្យព្រះអង្គគង់ ចំណែកឯក្បាលរបស់វាបើកពពារ ការពារទឹកភ្លៀង ខ្យល់ពីលើកុំឱ្យប៉ះពាល់ទឹកដល់ព្រះអង្គ បាន ឡើយ ។ ម្យ៉ាងទៀតតាមសភាព ជាក់ស្តែង ការយកនាគ-ជហ្វាមកប្រើប្រាស់លើសំណង់នេះគឺមើលទៅ ឃើញសោភ័ណភាពស្អាត សក្តិសមនឹង សំណង់បំពីឱ្យ សាសនាផង ដែលពុំអាចយកអ្វីក្រៅផ្សេងទៀតមកជំនួសបាន ពេលដាក់ប្រើទៅមិន សមល្អដូចប្រើនាគ-ជហ្វាឡើយ។




**ខ្នាតជហ្វា** :

កំពស់ជហ្វាគឺយកកំពស់ហោជាងចែកជា៣ចំណែក (ទី១) ហើយយក១ចំណែកមកចែក ជា៤ផ្នែកទៀត (ទី២)នោះយើងនឹងបានកំពស់របស់ជហ្វាមួយដែល បំពាក់លើសំណង់ នោះទៅ សមល្អមិនខុសខ្នាត, សមភ្លែក។

ឧទាហរណ៍: កំពស់ហោជាងមួយ ៦ម៉ែត្រ។ យើងត្រូវយកកំពស់ជហ្វាប៉ុន្មានទើបសមល្អ

ទី១ : ៦ម៉ែត្រ : ៣ = ២ម៉ែត្រ
ទី២ : ២ម៉ែត្រ : ៤ = ០,៥ម៉ែត្រ

កំពស់ជហ្វា=ទី១+ទី២=២ម៉ែត្រ + ០,៥ម៉ែត្រ
= ២,៥ម៉ែត្រ



www.budinst.gov.kh www.elibraryofcambodia.org

## ៥.៤.៨ ហោជាង

ហោជាង=ហោ + ជាង គឺជាវាំងននដែលដាក់ត្រង់ខាងក្រោមចុងដំបូលគ្រឹះហា ឬសាលាជាដើមមានសណ្ឋានបីជ្រុង ធ្វើជាឋានលាតក៏មានឆ្លាក់ឬគូរក្បាច់របាំងផ្សេងៗក៏មាន ។ ហោជាងធ្វើពីសំភារៈច្រើនប្រភេទដូចជា ស្លឹក (ត្នោត,ចាក, ដូង...) ឈើ, ជាយអរ, បេតុង ។ល។ ម្យ៉ាងទៀត ហោជាងស្មើនឹងពាក្យក្នុងភាសាសៀមថា ហូឆាង មានន័យជាត្រចៀកដំរី (ហោជាង=ហូ + ឆាង) ។

សំណង់ព្រះវិហារមានហោជាង២ឬ៤ទៅតាមប្លង់និងតាមចិត្តអ្នកកសាងចង់បាន ប៉ុន្តែខុសគ្នាហើយវិការអស់ច្រើន និងតិចជាងប៉ុណ្ណោះ ។ ប្រសិនបើធ្វើហោជាង២ គឺបែរទៅទិស ខាងកើតនិងខាងលិច តែបើធ្វើហោជាង៤ គឺបែរទៅទិសទាំងទាំង៤ដែរ ហើយមានន័យផ្សេងៗពីគ្នាផងដែរ។ អត្ថន័យរបស់ហោជាងទាំង៤ នោះមានដូចតទៅ : ហោជាងបែរទៅទិសខាងកើតគឺផ្ចាញ់មារ, ទិសខាងត្បូងគឺត្រាស់បញ្ចាររស្មី,ទិសខាងលិច គឺបរិនិព្វាន និងទិសខាងជើងគឺប្រសូត្រ ។ ជួនកាលគេឱ្យន័យផ្សេងៗទៀតដែលសំខាន់ៗ នៅក្នុងព្រះពុទ្ធសាសនា ។

តាំងពីដើមមក (មើលប្រវត្តិវត្តអារាម) នៅក្នុងហោជាងព្រះវិហារច្រើនប្រើរូប ចាម់ជង្គដោយរូបអក្សរម្យនៅចំកណ្ដាលហោជាង។ លើសពីនេះមានការរចនារំលេចដោយសំណាញ់ផ្សេងៗ ឬបំណែកកញ្ចក់ជាហេតុធ្វើឱ្យក្បាច់ និងរូបឆ្លាក់លេចធ្លុសឡើងបន្ថែមសោភ័ណភាពថែមទៀត ។ ម្យ៉ាងទៀតនៅក្នុងហោជាងទាំងមូលឆ្លាក់ក្បាច់សុទ្ធក៏មាន ហើយក្បាច់ទាំងនោះយកមកប្រើប្រាស់មានដូចជា : ក្បាច់ភ្ញីភ្លើង ,ភ្ញីទេស, ភ្ញីវល្លិ៍, ក្បាច់ទេសក្ខាយជាដើម ។

ប៉ុន្តែចំពោះក្បាច់ភ្ញីភ្លើងមួយគឺគេមិនយកទៅប្រើប្រាស់ណាស់ បើសិនជាយក ទៅប្រើលុះត្រាតែលោកសង្ឃឬចៅអធិការវត្ត ឬបុគ្គលណាដែលមានសិទ្ធិអំណាច ឋានៈ យសសក្តិខ្ពង់ខ្ពស់ហើយ និងជាវង្សត្រកូលក្សត្រ ទើបអាចប្រើប្រាស់បាន ។ ចំណែកក្បាច់ផ្សេងៗទៀតប្រើប្រាស់ក្នុងលក្ខណៈសាមញ្ញ និយាយឱ្យងាយស្ដាប់គឺប្រើតាមចិត្តចង់។

### ក្បួនខ្នាតហោជាង

តាមការសិក្សាស្រាវជ្រាវពីសំណាក់លោកអាចារ្យមានវ័យចំណាស់ៗផង ពីជាងសំណង់ខ្មែរបុរាណផង និងពីលោកគ្រូស្ថាបត្យកម្មខ្មែរផងនោះបានទទួលលទ្ធផលគឺ ក្បួន២របៀប ផ្សេងៗគ្នាហើយកំណត់កំពស់ហោជាងក៏ខុសគ្នាដែរ ប៉ុន្តែអាចយកមកប្រើការបានទាំង២ក្បួន ។



www.budinst.gov.kh www.elibraryofcambodia.org

-<u>ក្បួនទី១</u> : កំពស់ហោជាងគឺយកបាតរបស់ហោជាង (ប្រវែងឈមនឹងដំបូល=ទ្រឹម) ចែកជា ៣ចំណែក (ខ្នាត) ហើយយក១ខ្នាតទៅចែកជា៣ផ្នែកទៀត (ខ្នាត) នាំឲ្យបានកំពស់ហោជាស្មើនឹង២ខ្នាត ចែកលើកទី១បូកបញ្ចូលជាមួយនិង ២ខ្នាតចែកលើកទី២ ។

| (២ខ្នាតលើកទីមួយ) + (២ខ្នាតលើកទី២) = កំពស់ហោជាង |
|---|

<u>ការសន្និដ្ឋាន</u> : ការគណនាតាមក្បួនខ្នាតនេះហោជាងគឺជាត្រីកោណសម័ង្ស ដែលមុំក្នុងស្មើនឹង ៦០អង្សាជានិច្ច ទោះបីបាតហោជាង (ទ្រឹម) តូចឬធំ ឬការបើកល្វែង (គំលាតពីសសរមួយទៅសសរមួយទៀត) ក៏ដោយគឺមិនទាក់ទងឡើយ ។

-<u>ក្បួនទី២</u> : ដើម្បីរកកំពស់ហោជាងមួយគឺយកប្រវែងបាតហោជាង (ទ្រឹម) ចែកនឹង៨ ហើយគុណនឹង៧ ។

$$\text{កំពស់ហោជាង} = \frac{\text{ទ្រឹម} \times ៧}{៨}$$

<u>ការសន្និដ្ឋាន</u> : តាមក្បួនទី២នេះ ហោជាងជាត្រីកោណសមបាតដែលមានមុំបាតស្មើនឹង៦០អង្សាជានិច្ច មិនអាស្រ័យទៅនឹងប្រវែងបាតហោជាងទេទោះបីធំឬតូចក៏ដោយ ។

©©©◆©©©



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ហោជាងទ្រូ






www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org



ក្បាច់ហោជាង

ក្បាច់ភ្ញីទេស



ក្បាច់ភ្ញីត្បូង



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org